# ឯកសារសង្ខេបអំពីដៃគូអនុវត្តគម្រោង
# ផ្នែកពិការភាពនៃកម្មវិធី ACCESS

## សង្ខេបគម្រោង

អង្គការ HI (ដែលមានឈ្មោះប្រតិបត្តិការថា អង្គការជនពិការអន្តរជាតិ) កំពុងធ្វើការជាដៃគូជាមួយរដ្ឋាភិបាល អង្គការតំណាងជនមានពិការភាព (DPOs)  មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា (PRCs) និង គ្រឹះស្ថានសុខាភិបាលផ្សេងៗ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP ២០១៩-២០២៣) ។ គម្រោងនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាកម្មប្រកបដោយគុណភាព និងបរិយាបន្ន សម្រាប់ទាំងអស់គ្នារួមទាំងស្ត្រី និងជនមានពិការភាព។

## លទ្ធផលរំពឹងទុករបស់គម្រោង

- គាំទ្រដល់ ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការអនុវត្តបទដ្ឋានបច្ចេកទេសថ្នាក់ជាតិស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ប្រកបដោយប្រសិទ្ធភាព។
- គាំទ្រដល់ មូលនិធិជនពិការក្នុងការគ្រប់គ្រង មជ្ឈមណ្ឌលស្តារគោលដៅ ប្រកបដោយប្រសិទ្ធភាព។
- គាំទ្រ មន្ត្រីថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ការរៀបចំកម្មវិធីវិនិយោគឃុំ/សង្កាត់ប្រកបដោយបរិយាបន្ន ព្រមទាំងជម្រុញអោយមានការចូលរួមរបស់អង្គការតំណាងជនពិការដើម្បីធ្វើប្រសើរឡើងក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ/សង្កាត់នេះ។

## កិច្ចអន្តរាគមន៍សំខាន់ៗ

- ចងក្រងឯកសារបណ្តុះបណ្តាល និងផ្តល់ការបណ្តុះបណ្តាលស្តីពីបទដ្ឋានបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។
- ធ្វើសវនកម្មលើបរិយាបន្នដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពលើមធ្យោបាយធ្វើដំណើរ។
- គាំទ្រដល់ការអនុវត្ត គោលការណ៍ណែនាំថ្មីស្តីពីកញ្ចប់សេវាកម្មអប្បបរមា របស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា(PRC-MPS) រួមទាំង ការណែនាំអំពីប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃសេវាស្តារ និងការរៀបចំការងារហិរញ្ញប្បទានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា។

- បណ្តុះបណ្តាល និងបង្វឹកប្រធានមណ្ឌលស្តារ និងបុគ្គលិកនៃមូលនិធិជនពិការ លើភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងអភិបាលកិច្ច ព្រមទាំងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។
- គាំទ្រដល់ការចូលរួមរបស់អង្គការតំណាងជនមានពិការភាពទៅក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគឃុំ/សង្កាត់។

**កិច្ចអន្តរាគមន៍ជាពិសេស ចំពោះការទប់ស្កាត់ការរីករាលមេរោគ កូវីដ-១៩**

- សហការ និងចូលរួមក្រុមការងារបច្ចេកទេស ក្នុងការបង្កើតអោយមានផ្ទាំងរូបភាពអប់រំដែលងាយស្រួលអានស្តីពីមេរោគ កូវីដ-១៩ និងចែករំលែក ផ្សព្វផ្សាយសម្ភារៈអប់រំទៅកាន់តំបន់គោលដៅ
- តៀងគរធនធាន បុគ្គលិកក្នុងការផ្តល់ព័ត៌មានដល់ជនមានពិការភាព អំពីការបង្ការមេរោគកូវីដ-១៩  និងកំណត់រកការបញ្ជូនមានលក្ខណៈសមស្រប។
- បង្កើតឯកសារសង្ខេប ស្តីពីការបង្កលក្ខណៈងាយស្រួលនៅមូលដ្ឋានព្យាបាល និងថែទាំសុខភាព និងផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណែតទៅកាន់ប្រធានមន្ទីរពេទ្យ និងមណ្ឌលសុខភាពនានា។
- រៀបចំបង្កើតប្រព័ន្ធស្តារលទ្ធភាពពលកម្មកាយសម្បទា ពីចម្ងាយនៅមណ្ឌលស្តារខេត្តកំពង់ចាម។

**ក្រុមគោលដៅ**

- ក្រុមគោលដៅផ្ទាល់៖ អ្នកទទួលសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា មូលនិធិជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា  អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រុមប្រឹក្សាឃុំសង្កាត់ និងអង្គការតំណាងជនពិការជួយខ្លួនឯង ស្រុកបាធាយ។
- ក្រុមគោលដៅប្រយោល៖ ស្រ្តី និងបុរសមានពិការភាព រួមទាំងគ្រួសាររបស់គេ។

**តំបន់គោលដៅ**

សាខាមូលនិធិជនពិការខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាក្នុងខេត្តសៀមរាប តាកែវ ក្រចេះ ព្រៃវែង រាជធានីភ្នំពេញ និងការគាំទ្រនៅថ្នាក់ជាតិ ព្រមទាំងខេត្តផ្សេងទៀតសម្រាប់ការអនុវត្តបទដ្ឋានបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព

**ដៃគូអនុវត្តគម្រោង**

មូលនិធិជនពិការ រួមទាំងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ និងអង្គការតំណាងជនពិការជួយខ្លួនឯង ស្រុកបាធាយ

**រយៈពេលអនុវត្តគម្រោង**

ខែកញ្ញា ឆ្នាំ ២០១៩ ដល់ ខែមិថុនា ឆ្នាំ ២០២១

**ថវិកាគម្រោង**

ថវិកាសរុប៖ AUD ៦១៧,៨០៨ (ថវិកាពី ACCESS៖ AUD ៥៥១,៧៥០)

| ព័ត៌មានទំនាក់ទំនង | |
|---|---|
| អង្គការ (HI)<br>លោកស្រី Edith van Wijngaarden<br>ប្រធានប្រចាំប្រទេស<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៩៩៥ ២៣៩<br>អ៊ីម៉ែល៖ e.van-wijngaarden@hi.org | កម្មវិធី ACCESS<br>លោក ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ vivath.ch@accesscambodia.org |

គម្រោងនេះឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី សហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីសេវាប្រកបដោយសមធម៌ និងនិរន្តរភាព(ACCESS)។

ខែឧសភា ឆ្នាំ២០២០